# សេចក្ដីជូនដំណឹង

សាសនាចក្រនៃ
**ព្រះយេស៊ូវគ្រីស្ទ**
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

កាលបរិច្ឆេទ ៖ ថ្ងៃ ទី ១០ ខែ មិនា ឆ្នាំ ២០១៤

ជូនចំពោះ៖ ពួកអ្នកមានសិទ្ធិអំណាចទូទៅ ពួកចិតសិបនាក់ប្រចាំតំបន់ ប្រធាន បេសកកម្មប្រធានស្ដេក និងប្រធានមណ្ឌល ប៊ីស្សព និងប្រធានសាខាទាំងឡាយ

មកពី ៖ ការិយាល័យផ្នែកអ្នកផ្សព្វផ្សាយសាសនា ( ៨០១-២៤០-២២២២ )

កម្មវត្ថុ ៖ ការពិនិត្យរកមើលរោគរបេង សម្រាប់ពួកអ្នកផ្សព្វផ្សាយសាសនាត្រឡប់ពីបេសកកម្មវិញ

---

របេងគឺជាមេរោគឆ្លងដ៏ធ្ងន់ធ្ងរដែលអាចបំផ្លាញសួត និងសរីរាង្គសំខាន់ៗផ្សេងទៀត ។ វាសំខាន់បំផុតដែលពួកអ្នកផ្សព្វផ្សាយសាសនាត្រឡប់ពីបេសកកម្មវិញ ត្រូវពិនិត្យរកមើលជំងឺរបេង ពីព្រោះពួកគេអាចឆ្លងមេរោគនោះ ដោយមិនទាន់មានរោគសញ្ញាបង្ហាញភ្លាមៗ ។

សំបុត្រភ្ជាប់គឺជាសំបុត្រដែលប្រធានបេសកកម្ម នឹងប្រគល់ជូនពួកអ្នកផ្សព្វផ្សាយសាសនា ដែលត្រឡប់មកពីបេសកកម្មវិញ ដោយណែនាំពួកគេឲ្យទៅពិនិត្យរកមើលរោគរបេងជាបន្ទាន់ បន្ទាប់ពីពួកគេត្រឡប់មកផ្ទះវិញ ។ សំបុត្រចម្លងជាអេឡិចត្រូនិចអាច ទាញយកឯកសារ ដោយប្រធានបេសកកម្ម ដកស្រង់ចេញពី Mission President’s Portal ( missionary.lds.org/presidents ) ឬដោយបុគ្គលិកការិយាល័យរបស់បេសកកម្ម តាមរយៈវែបសាយ Missionary Medical website ( missionarymedical.org ) ។

យើងស្នើសុំដល់ពួកអ្នកដឹកនាំបព្វជិតភាពក្នុងមូលដ្ឋាន ឲ្យលើកទឹកចិត្តដល់ពួកអ្នកផ្សព្វផ្សាយដែលត្រឡប់មកវិញទៅពិនិត្យរកមើលរោគរបេង នៅពេលដែលពួកគេត្រឡប់មកផ្ទះវិញ ហើយត្រូវប្រាកដថា ពួកគេមានធនធានគ្រប់គ្រាន់ ដើម្បីទទួលបាននូវការថែទាំនេះ ។

ការបកប្រែនៃ *Notice, 10 March 2014*: *Tuberculosis Screening for Returning Missionaries*. Cambodian. 12100 258

ជូនចំពោះអែលឌើរ/ស៊ិសស្ទើ _______________៖

កម្មវត្ថុ ៖ការពិនិត្យរកមើលរោគរបេង

របេង គឺជាជំងឺឆ្លងដ៏ធ្ងន់ធ្ងរដែលអាចបំផ្លាញសួត និងសរីរាង្គសំខាន់ៗផ្សេងទៀត ។ ជាទូទៅ វាជាជម្ងឺដែលឆ្លងច្រើនជាងគេ ដែលមនុស្សមួយភាគបីនៃពិភពលោកយើងទាំងមូលមានផ្ទុកនូវមេរោគនេះ ។ អ្នកដែលឆ្លងជម្ងឺនេះ គឺមានក្អកជាញឹកញាប់ ជាទូទៅចម្លងទៅដល់អ្នកដទៃទៀត ។

មនុស្សភាគច្រើនដែលឆ្លងមេរោគរបេង គឺមិនបានដឹងពីរោគសញ្ញានោះភ្លាមៗទេ ។ ដែលត្រូវបានគេហៅថា របេងសំងំ ។ អស់អ្នកដែលមានរបេងសំងំ គឺមានឱកាស ១០ ភាគរយ ឈឺជំងឺនេះនៅពេលក្រោយ ។

ដើម្បីកុំឲ្យខ្លួនទទួលប្រឈមនឹងរោគសញ្ញាធ្ងន់ធ្ងរនៃការមានជំងឺរបេង ដូច្នេះ វាសំខាន់ខ្លាំងណាស់ ដែលអ្នកត្រូវទៅពិនិត្យរកមើលរោគរបេងឲ្យបានលឿនបំផុត តាមដែលអាចធ្វើបានបន្ទាប់ពីត្រឡប់មកផ្ទះវិញ ។ ទោះបីជាលទ្ធផលពិនិត្យ ជម្ងឺរបេងពីមុនបេសកកម្មរបស់អ្នកយ៉ាងណាក្តី (ទោះជាវិជ្ជមាន ឬអវិជ្ជមានក្តី ) អ្នកនៅតែត្រូវជួបគ្រូពេទ្យ ឬទៅមណ្ឌលពិនិត្យសុខភាពដើម្បីពិនិត្យម្តងទៀត ពេលអ្នកត្រឡប់មកផ្ទះវិញ ។ ការពិនិត្យ ឬការព្យាបាលបន្ថែមក៏មានសារៈសំខាន់ផងដែរ ។

ប្រសិនបើអ្នកត្រូវបានធ្វើរោគវិនិច្ឆ័យឃើញថា មានរោគរបេងសំងំ នោះអ្នកគួរតែធ្វើតាមការប្រឹក្សាយោបល់របស់វេជ្ជបណ្ឌិត ឬមណ្ឌលពិនិត្យសុខភាពនៅក្នុងមូលដ្ឋានរបស់អ្នក តាមគោលនយោបាយសុខភាពនៃប្រទេសរបស់អ្នក ។ សូមអរគុណចំពោះការថែទាំសុខភាពរបស់អ្នក ដើម្បីអ្នកអាចបន្តធ្វើជាអ្នកបម្រើរបស់ព្រះអម្ចាស់ដ៏រឹងមាំ និងមានសុខភាពល្អ ពេញមួយជីវិតរបស់អ្នក ។

ដោយសេចក្តីស្មោះស្ម័គ្រ

_______________________________

ប្រធានបេសកកម្ម